កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

WFP World Food Programme

# សេចក្តីប្រកាសព័ត៌មានរួម
# របស់កម្មវិធីស្បៀងអាហារពិភពលោក និងជីអាយហ្ស៊ិត

**អាល្លឺម៉ង់និងកម្មវិធីស្បៀងអាហារពិភពលោកផ្តល់ជំនួយជាសាច់ប្រាក់ដើម្បីគាំទ្រដល់ក្រុមគ្រួសារនៅកម្ពុជាដែលរងផលប៉ះពាល់ដោយសារកូវីដ-១៩ និងគ្រោះមហន្តរាយអាកាសធាតុ។**

រាជធានីភ្នំពេញ៖ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់និងកម្មវិធីស្បៀងអាហារពិភពលោកបានកសាងភាពជាដៃគូថ្មីមួយ ដើម្បីគាំទ្រដល់ក្រុមគ្រួសារនៅកម្ពុជាដែលមានចំណូលទាប និងរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ-១៩ និងគ្រោះមហន្តរាយដោយសារអាកាសធាតុ។ តាងនាមឱ្យក្រសួងសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងអភិវឌ្ឍអាល្លឺម៉ង់ (BMZ) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (ជីអាយហ្ស៊ិត) បានផ្តល់ជំនួយចំនួន៥លានអឺរ៉ូ ដែលស្មើនឹងប្រមាណ៦លានដុល្លារអាមេរិកដើម្បីផ្តល់ជំនួយជាសាច់ប្រាក់ដល់ក្រុមគ្រួសាររងគ្រោះ ក្នុងបំណងរួមចំណែកស្តារនូវស្ថានភាពរបស់ក្រុមគ្រួសារឡើងវិញ។ ភាពជាដៃគូនេះនឹងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់លទ្ធភាពឆ្លើយតបរបស់គម្រោងគាំពារសង្គម ដើម្បីពង្រឹងភាពធន់ទៅនឹងវិបត្តិ។

ជំងឺរាតត្បាតកូវីដ-១៩នេះបានជះឥទ្ធិពលផ្នែកសង្គមនិងសេដ្ឋកិច្ចយ៉ាងខ្លាំងទៅលើប្រជាជនកម្ពុជាដែលងាយរងគ្រោះ។ វិបត្តិអាកាសធាតុ ឧទាហរណ៍ដូចជា គ្រោះទឹកជំនន់នៅចុងឆ្នាំ២០២០ បានបង្កឱ្យស្ថានភាពអវិជ្ជមានមួយចំនួនកាន់តែធ្ងន់ធ្ងរឡើង។

លោកស្រី **ក្លែរ កូណាន់** តំណាងកម្មវិធីស្បៀងអាហារពិភពលោកបានលើកឡើងថា "កូវីដ-១៩ និងគ្រោះទឹកជំនន់បានបន្ថែមបន្ទុកចំពោះប្រជាជនដែលកំពុងតែជួបប្រទះនឹងបញ្ហាប្រឈមនានាស្រាប់ទៅហើយ។ របាយការណ៍បានបង្ហាញថា ក្រុមគ្រួសារងាយរងគ្រោះដែលរងផលប៉ះពាល់ដោយសារវិបត្តិទាំងពីរនេះ បានកាត់បន្ថយការទទួលទានអាហារ លក់ទ្រព្យសម្បត្តិ និងខ្ចីបំណុលបន្ថែមដើម្បីបំពេញតម្រូវការចាំបាច់។ យើងពិតជាពេញចិត្តណាស់ក្នុងការជួយដល់ប្រជាជនខ្វះខាតដើម្បីបំពេញតម្រូវការស្បៀងនិងអាហារូបត្ថម្ភ និងជួយសង្គ្រោះស្ថានភាពរបស់ពួកគាត់ឡើងវិញ។"

ជីអាយហ្ស៊ិត និងកម្មវិធីស្បៀងអាហារពិភពលោកនឹងប្រើប្រាស់ទិន្នន័យពីរាជរដ្ឋាភិបាលកម្ពុជា ដូចជាប្រព័ន្ធទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រ (IDPoor) របស់ក្រសួងផែនការ និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍និងអង្កេតតាមដានស្ថានការណ៍គ្រោះមហន្តរាយ (PRISM) ដើម្បីកំណត់អត្តសញ្ញាណក្រុមគ្រួសារក្រីក្រដែលរងគ្រោះដោយសារទឹកជំនន់ និងកូវីដ-១៩។ ជីអាយហ្ស៊ិតបានផ្តល់ការគាំទ្រផ្នែក

បច្ចេកទេសដល់ក្រសួងផែនការដើម្បីអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រអស់រយៈពេលជាងមួយទសវត្សរ៍មកហើយ។ បច្ចុប្បន្ននេះ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រគ្របដណ្តប់១០០% នៃតំបន់ជនបទនិងទីក្រុងនៅទូទាំងប្រទេសកម្ពុជា។

ក្រុមគ្រួសារគោលដៅនឹងទទួលបានជំនួយជាសាច់ប្រាក់ បន្ថែមពីលើជំនួយសង្គ្រោះបន្ទាន់ជាសាច់ប្រាក់សម្រាប់ទប់ទល់នឹងស្ថានភាពកូវីដ-១៩របស់រាជរដ្ឋាភិបាល។ ជំនួយបន្ថែមនេះនឹងជួយបង្ការមិនឱ្យក្រុមគ្រួសារបន្តធ្លាក់ចូលជ្រៅទៅក្នុងភាពក្រីក្រ និងជួយពង្រឹងភាពធន់របស់ពួកគាត់ចំពោះវិបត្តិនាពេលអនាគត។

ស្ថានភាពកូវីដ-១៩នៅមិនទាន់មានភាពប្រាកដប្រជានៅឡើយ ចំណែកវិបត្តិផ្នែកអាកាសធាតុនៅតែបង្កជាហានិភ័យជាប្រចាំ ហេតុដូច្នេះការត្រៀមលក្ខណៈទប់ទល់នឹងស្ថានភាពនេះមានសារៈសំខាន់ណាស់។ ដូច្នេះ កម្មវិធីស្បៀងអាហារពិភពលោកនិងជីអាយហ្សិតនឹងបន្តផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់លទ្ធភាពឆ្លើយតបរបស់គម្រោងគាំពារសង្គម ដើម្បីទប់ទល់នឹងវិបត្តិនានា។

ឯកឧត្តម **Christian BERGER** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់មានប្រសាសន៍ថា "សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់មានមោទនភាពដែលបានគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសាក្រីក្រ ជាមួយប្រទេសអូស្រ្តាលីអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមក។ ក្នុងសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការផ្នែកបច្ចេកទេសរបស់យើង(ជីអាយហ្សិត) ក្រសួងផែនការបានបន្តកែលម្អកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាបន្តបន្ទាប់ ហើយបច្ចុប្បន្ននេះ ការចុះបញ្ជីបានគ្របដណ្តប់ទូទាំងប្រទេសកម្ពុជា។ កម្មវិធីនេះមានអត្ថប្រយោជន៍ណាស់ក្នុងការឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។"

ឯកឧត្តមបានបញ្ជាក់បន្ថែមថា "នៅក្នុងកិច្ចសហការបន្ថែមជាមួយកម្មវិធីស្បៀងអាហារពិភពលោកនេះ យើងប្រើវិធីសាស្រ្តដែលមានមូលដ្ឋានលើប្រព័ន្ធទិន្នន័យ ដោយប្រើកម្មវិធីអត្តសញ្ញាណកម្មក្រុមគ្រួសារក្រីក្រ និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍និងអង្កេតតាមដានស្ថានការណ៍គ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះនិងកសាងភាពធន់សម្រាប់ក្រុមប្រជាជនងាយរងគ្រោះ រួមទាំងកុមារ មនុស្សចាស់ និងស្រ្តីផងដែរ។"

លោកស្រីកូណាន់បានបញ្ជាក់បន្ថែមថា "យើងសូមថ្លែងអំណរគុណដល់ប្រទេសអាល្លឺម៉ង់ដែលបានផ្តល់ការគាំទ្ររយៈពេលវែងដល់ប្រទេសកម្ពុជា ហើយយើងមានឆន្ទៈក្នុងការសហការយ៉ាងជិតស្និទ្ធជាមួយជីអាយហ្សិត ដើម្បីគាំទ្រដល់ក្រុមគ្រួសាររងគ្រោះដោយសារវិបត្តិនានាតាំងពីឆ្នាំមុន។ យើង

មានបំណងអភិវឌ្ឍគំរូប្រតិបត្តិការសម្រាប់កិច្ចគាំពារសង្គមទប់ទល់នឹងវិបត្តិនាពេលអនាគត សម្រាប់កម្ពុជា។ ធ្វើដូច្នេះ យើងនឹងអាចមានលទ្ធភាពរិះរកវិធីថ្មីៗដើម្បីលើកកម្ពស់កម្មវិធីជំនួយសង្គមនិងកម្មវិធីឆ្លើយតបនឹងគ្រោះមហន្តរាយ ដែលនឹងជួយឱ្យក្រុមគ្រួសារងាយរងគ្រោះបានត្រៀមខ្លួនកាន់តែប្រសើរនិងមានភាពធន់ នៅពេលមានវិបត្តិកើតឡើងនាពេលអនាគត។

ភាពជាដៃគូនេះនឹងជួយគាំទ្របន្ថែមដល់កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នរដ្ឋដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងផែនការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាដៃគូអភិវឌ្ឍនានាដែលបានចូលរួមចំណែកក្នុងផ្នែកជំនួយគាំពារសង្គមនិងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។

###

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោកស្រី ជា ជូ
មន្ត្រីផ្នែកទំនាក់ទំនងនិងរបាយការណ៍
កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា
ទូរស័ព្ទលេខ៖ +855 78 565 283
អ៊ីម៉ែល៖ chou.chea@wfp.org

Sophie Hermanns
ទីប្រឹក្សា
កម្មវិធីគាំទ្រអត្តសញ្ញាណកម្មក្រុមគ្រួសារក្រីក្រ ជីអាយហ្សិត
អ៊ីម៉ែល៖ sophie.hermanns1@giz.de

Martin Rentsch
ប្រធានផ្នែកទំនាក់ទំនង តស៊ូមតិ និងទីផ្សារ ទីក្រុងប៊ែរឡាំង
អ៊ីម៉ែល៖ martin.rentsch@wfp.org

###